# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ១២

## ឈ្មោះអត្តវគ្គ

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ១២

## ឈ្មោះអត្តវគ្គ

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# ខុទ្ទកនិកាយ គាថាធម្មបទ

## អត្តវគ្គ វគ្គទី ១២

*១ អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ*
*តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។*

*បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។*

*២ អត្តានមេវ បឋមំ បដិរូបេ និវេសយេ*
*អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។*

*បណ្ឌិតគួរតាំងខ្លួនទុក ក្នុងគុណដ៏សមគួរជាដាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ ( ធ្វើយ៉ាងនេះ ) នឹងមិនលំបាកឡើយ ។*

*៣ អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ*
*សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។*

*បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឯងឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មាន*

បានពេកណាស់ ។

៤ អត្តា ហិ អត្តនោ នាថោ  កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន  នាថំ លភតិ ទុល្លភំ

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្ដេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាន នូវទីពឹង ដែលគេបានដោយកម្រ ។

៥ អត្តនា ហិ កតំ បាបំ  អត្តជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ  វជិរំវម្ហយំ មណឹ ។

បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួន ធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រ សំរាប់កាត់កែវមណី ដែលកើតអំពីថ្មដូច្នោះឯង ។

៦ យស្ស អច្ចន្តទុស្សីល្យំ  មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ  យថា នំ ឥច្ឆតី ទិសោ ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ  គ្របសង្កត់ ( នូវអត្តភាព ) របស់បុគ្គលណា  ដូចវល្លិដែល រួបរឹតដើមឈើ បុគ្គលនោះឈ្មោះថា ធ្វើខ្លួនឯងឲ្យ វិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាស ដូច្នោះ ។

៧ សុករានិ អសាធូនិ  អត្តនោ អហិតានិ ច

យំ វេ ហិតញ្ច សាធុញ្ច    តំ វេ បរមទុក្ករំ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណា ជាប្រយោជន៍ផង ល្អផង កម្មនុ៎ះឯង ដែលជនពាលធ្វើបានដោយលំបាក ។

៨ យោ សាសនំ អរហតំ    អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ    ទិដ្ឋឹ និស្សាយ បាបិកំ
ផលានិ កណ្ដកស្សេវ    អត្តឃញ្ញាយ ផល្លតិ ។

បុគ្គលណា អប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនា របស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់ របស់បុគ្គលនោះ រមែងចេញផល ដើម្បីសំលាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ ។

៩ អត្តនា វ កតំ បាបំ    អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ    អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ    នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្ដីបរិសុទ្ធ និងមិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ

ឲ្យបរិសុទ្ធពុំបានទេ ។

**១០ អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ**

**អត្តទត្ថមភិញ្ញាយ សទត្ថប្បសុតោ សិយា ។**

បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ( នោះ ) ។

*********************

# ១២ អត្តវគ្គវណ្ណនា

## ១ រឿងពោធិរាជកុមារ

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងភេសកឡាវ័ន ទ្រង់ប្រារព្ធពោធិរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា “**អត្តានញ្ចេ**” ជាដើម ។*

### *ពោធិរាជកុមារសាងប្រាសាទហើយគិតសំលាប់ជាង*

*ដូចបានស្តាប់មក ពោធិរាជកុមារ ឲ្យជាងសាងប្រាសាទឈ្មោះ កោកនទៈ មានទ្រង់ទ្រាយមិនដូចប្រាសាទដទៃៗ លើផែនដី ដូចជាអណ្តែតព្ធដ៏អាកាស ហើយត្រាស់សួរជាងថា ប្រាសាទដែលមានរូបរាងយ៉ាងនេះ អ្នកធ្លាប់សាងក្នុងទីដទៃខ្លះហើយឬ ឬថា នេះជាសិល្បៈដំបូងរបស់អ្នក កាលជាងពោលថា បពិត្រព្រះសម្មតិទេព នេះជាសិល្បៈដំបូងបង្អស់របស់ខ្ញុំព្រះអង្គ ពោធិរាជកុមារទ្រង់តំរិះថា បើជាង*

នេះសាងប្រាសាទ ដែលមានរូបរាងយ៉ាងនេះ ដល់ជនដទៃ សោត, ប្រាសាទនេះក៏នឹងមិនគួរឲ្យអស្ចារ្យ, កាលដែលយើង សំលាប់ជាងនេះ កាត់ដៃ និងជើងរបស់គេ ឬខ្វះភ្នែកទាំង ពីរចេញ រមែងគួរ, កាលបើដូច្នោះ គេនឹងសាងប្រាសាទ ដល់ជនដទៃមិនបានឡើយ ព្រះអង្គបានប្រាប់សេចក្ដីនោះដល់ មាណពបុត្ររបស់សញ្ជីវក ដែលជាសំឡាញ់របស់ខ្លួន ។

## ជាងធ្វើសត្វគ្រុឌជិះគេចភ័យ

មាណពនោះ គិតថា ព្រះរាជកុមារអង្គនេះ នឹងបំផ្លាញ ជាងឲ្យវិនាស ដោយឥតសង្ស័យ, អ្នកដែលមានសិល្បៈ រកតំលៃមិនបាន, បើយើងនៅមាន គេចូរកុំវិនាសឡើយ, យើងនឹងសញ្ញាដល់គេ ។ មាណពនោះ ចូលទៅរកជាង ហើយ សួរថា "ការងាររបស់អ្នកត្រង់ប្រាសាទសំរេចហើយ ឬនៅ" កាលជាងប្រាប់ថា សំរេចហើយ ទើបពោលថា ព្រះ រាជកុមារមានបំណងនឹងសំលាប់អ្នក ព្រោះដូច្នោះ អ្នកត្រូវ រក្សាខ្លួនឲ្យល្អ ។

ជាងនិយាយថា នាយ លោកប្រាប់សេចក្ដីនោះដល់ខ្ញុំ ល្អហើយ, ខ្ញុំនឹងជ្រាបកិច្ចដែលគួរធ្វើក្នុងរឿងនេះ ដូច្នេះហើយ

កាលព្រះរាជកុមារត្រាស់សួរថា សំឡាញ់ ការងាររបស់អ្នក ត្រង់ប្រាសាទរបស់យើងសំរេចហើយឬ ? ទើបទូលថា បពិត្រ ព្រះសម្មតិទេព ការងារត្រង់ប្រាសាទ នៅមិនទាន់សំរេចទេ, នៅសល់ទៀតច្រើន ។

ព្រះរាជកុមារ. ការងារអ្វីនៅសល់ ?

ជាង. បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងទូលឲ្យទ្រង់ជ្រាបខាងក្រោយ, សូមព្រះអង្គត្រាស់បញ្ជាឲ្យនរណាៗ យកកំណាត់ឈើមកសិនចុះ ។

រាជកុមារ. នឹងឲ្យគេយកកំណាត់ឈើប្រភេទណាមក ?

ជាង. ឈើស្ងួត មិនមានសរសៃ ព្រះអង្គ ។

ព្រះអង្គ បានត្រាស់ឲ្យគេជញ្ជូនមកឲ្យហើយ លំដាប់នោះ ជាងទូលព្រះរាជកុមារនោះថា បពិត្រព្រះសម្មតិទេព ពីពេលនេះទៅ ព្រះអង្គមិនគប្បីមកកាន់សំណាក់ខ្ញុំព្រះអង្គ,ព្រោះកាលខ្ញុំព្រះអង្គធ្វើការងារដែលល្អិត កាលមានការសន្ទនាគ្នានឹងជនដទៃ ការរាយមាយក៏នឹងមាន, មួ៉ាងទៀត វេលាទទួលទានអាហារ ភរិយារបស់ខ្ញុំព្រះអង្គប៉ុណ្ណោះ នឹងនាំអាហារមក ។ ព្រះរាជកុមារទទួលថា ល្អហើយ ។ ចំណែកជាងអង្គុយចាំង

ឈើទាំងនោះនៅក្នុងបន្ទប់មួយ ធ្វើជាសត្វគ្រុឌ ដ៏គួរដល់បុត្រ និងកិរិយារបស់ខ្លួនអង្គុយខាងក្នុងបាន ក្នុងវេលាទទួលទានអាហារប្រាប់កិរិយាថា នាងចូរលក់របស់គ្រប់យ៉ាងដែលមាននៅក្នុងផ្ទះ ហើយកាន់តែយកតែមាស និងប្រាក់ទុក ។

## ជាងនាំក្រុមគ្រួសារគេចចេញ

ចំណែកព្រះរាជកុមារ ត្រាស់បញ្ជាឲ្យឡោមពទ្ធប្រាសាទទុក ទ្រង់ចាត់តាំងការរក្សា ដើម្បីប្រយោជន៍មិនឲ្យជាងចេញទៅបាន ។ ឯនាយជាង ក្នុងវេលាដែលសត្វសំរេចហើយបន្ទាប់កិរិយាថា ថ្ងៃនេះ នាងគប្បីនាំក្មេងទាំងអស់មក ទទួលទានអាហារព្រឹកស្រេចហើយ ឲ្យបុត្រ និងកិរិយាអង្គុយក្នុងពោះសត្វគ្រុឌ គេចចេញតាមបង្អួចទៅ ។ កាលពួកអារក្ខាទាំងនោះកន្ទក់កន្ទេញទូលថា បពិត្រព្រះសម្មតិទេព ជាងលបចេញទៅបានហើយ ដូច្នេះនោះឯង ជាងនោះក៏ទៅចុះត្រង់ហិមវន្តប្រទេសសាងនគរមួយ បានជាព្រះរាជា ទ្រង់ព្រះនាមថា កដ្ឋវាហនៈ ក្នុងនគរនោះ ។

## ព្រះសាស្តាមិនទ្រង់ជាន់សំពត់កំរាល

ចំណែកព្រះរាជកុមារទ្រង់ត្រិះថា យើងនឹងធ្វើការឆ្លង ប្រាសាទ ទើបត្រាស់ឲ្យនិមន្តព្រះសាស្តា ទ្រង់ធ្វើការប្រស់ព្រំ ក្នុងប្រាសាទដោយរបស់ក្រអូប ដែលផ្សំគ្នា ៤ យ៉ាង ទ្រង់ ក្រាលផ្ទាំងសំពត់តាំងអំពីធរណីជំបូងមក ។ បានឮថា ព្រះអង្គ មិនមានព្រះឱរស ព្រោះដូច្នោះ ទើបទ្រង់ត្រិះថា បើយើងនឹង បានបុត្រ ឬធីតាសោត, ព្រះសាស្តានឹងទ្រង់ជាន់ផ្ទាំងសំពត់ នេះ ទើបទ្រង់ក្រាល ។ ព្រះអង្គ កាលព្រះសាស្តាស្តេចមក ថ្វាយបង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋានហើយ ទទួលបាត្រ ហើយក្រាបទូលថា សូមព្រះអង្គស្តេចចូលទៅចុះ ព្រះអង្គ ។ ព្រះសាស្តាមិនស្តេចចូលទៅ ។ ព្រះអង្គទ្រង់អង្វរដល់ ២-៣ ដង ព្រះសាស្តាក៏នៅមិនស្តេចចូលទៅ ទ្រង់បានបែរមើលព្រះ អានន្ទ ។ ព្រះថេរៈជ្រាបការដែលមិនទ្រង់ជាន់សំពត់ទាំងឡាយ ដោយសញ្ញាដែលព្រះអង្គទ្រង់ក្រឡេកមើលនោះឯង ទើបទូល ឲ្យព្រះរាជកុមារ ប្រមូលសំពត់ទាំងឡាយចេញ ដោយពាក្យ ថា ព្រះរាជកុមារ សូមព្រះអង្គប្រមូលសំពត់ទាំងឡាយចេញ ចុះ, ព្រះមានព្រះភាគ មិនទ្រង់ជាន់ផ្ទាំងសំពត់ ព្រោះព្រះ-តថាគត ទ្រង់សំឡឹងឃើញពួកជនជំនាន់ក្រោយ ។

# ព្រះសាស្ដាត្រាស់ហេតុដែលមិនទ្រង់ជាន់សំពត់

ព្រះរាជកុមារទ្រង់ប្រមូលសំពត់ទាំងឡាយហើយ ទូលនិមន្តព្រះសាស្ដាឲ្យស្ដេចចូលទៅខាងក្នុង ទ្រង់អង្គាសឲ្យស្កប់ស្កល់ដោយយាគូ និងបង្អែមហើយ គង់នៅត្រង់ចំណែកម្ខាងថ្វាយបង្គំហើយ ទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាឧបដ្ឋាករបស់ព្រះអង្គ ដល់ព្រះអង្គជាទីពឹង ៣ ដងហើយ គឺខ្ញុំព្រះអង្គនៅក្នុងផ្ទៃ ដល់ព្រះអង្គជាទីពឹងម្ដង លើកទីពីរក្នុងគ្រាដែលខ្ញុំព្រះអង្គនៅជាក្មេងតូច, ចំណែកលើកទី ៣ ក្នុងកាលដែលខ្ញុំព្រះអង្គដល់ភាពជាអ្នកដឹងក្ដី, ព្រះអង្គមិនទ្រង់ជាន់ផ្ទាំងសំពត់របស់ខ្ញុំព្រះអង្គនោះ ព្រោះហេតុអ្វី ?

ព្រះសាស្ដា. រាជកុមារ ចុះព្រះអង្គត្រិះរិះយ៉ាងណា ទើបក្រាលផ្ទាំងសំពត់ ?

រាជកុមារ. បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគិតដូច្នេះថា បើយើងនឹងបានបុត្រ ឬធីតាសោត, ព្រះសាស្ដានឹងទ្រង់ជាន់ផ្ទាំងសំពត់របស់យើង ទើបក្រាលផ្ទាំងសំពត់ ។

ព្រះសាស្ដា. ព្រោះហេតុនោះ តថាគតទើបមិនជាន់ ។

រាជកុមារ. បពិត្រព្រះអង្គដ៏ចំរើន ចុះខ្ញុំព្រះអង្គមិនបាន បុត្រ ឬធីតាពិតមែនឬ ?

ព្រះសាស្តា. ពិតមែនហើយ រាជកុមារ ។

រាជកុមារ. ព្រោះហេតុអ្វី ព្រះអង្គ ?

ព្រះសាស្តា. ព្រោះការដែលព្រះអង្គ និងព្រះជាយា ជាអ្នកមានសេចក្តីប្រមាទក្នុងអត្តភាពមុន ។

រាជកុមារ. ក្នុងកាលណា ព្រះអង្គ ?

## បុព្វកម្មរបស់ពោធិរាជកុមារ

លំដាប់នោះ ព្រះសាស្តា ទ្រង់នាំអតីតនិទានមកសំដែងប្រាប់ព្រះរាជកុមារនោះ ៖

ដូចបានស្តាប់មក ក្នុងអតីតកាល មនុស្សជាច្រើននាក់ជិះសំពៅទៅកាន់មហាសមុទ្ទ ។ សំពៅបានក្រឡាប់កណ្តាលសមុទ្ទ ពីរនាក់ស្វាមីភរិយាប្រវេប្រវាបានផែនក្តារមួយ ហែលចូលទៅកាន់កោះតូច ដែលមាននៅក្នុងចន្លោះ, មនុស្សដ៏សេសបានស្លាប់ក្នុងមហាសមុទ្ទនោះឯងទាំងអស់ ។ ក៏ពួកសត្វស្លាបជាច្រើន រស់នៅលើកោះនោះឯង, ពីរនាក់ប្តីប្រពន្ធមិនឃើញវត្ថុដទៃដែលគួរ បរិភោគបាន ត្រូវសេចក្តីស្រេកឃ្លានគ្រប

សង្កត់ ក៏ដុតពងសត្វទាំងឡាយហើយបរិភោគ, កាលពងសត្វទាំងនោះមិនគ្រប់គ្រាន់ ក៏ចាប់កូនសត្វទាំងឡាយអាំងស៊ី,កាលកូនទាំងនោះមិនគ្រប់គ្រាន់ ក៏ចាប់សត្វទាំងឡាយស៊ីទៀត, ក្នុងបឋមវ័យក្តី មជ្ឈិមវ័យក្តី បច្ឆិមវ័យក្តី បានបរិភោគយ៉ាងនេះឯង សូម្បីតែវ័យមួយក៏មិនមានសេចក្តីមិនប្រមាទ, មួយ៉ាងទៀតបណ្តាជនពីរនាក់នោះ សូម្បីតែម្នាក់ ក៏មិនបានដល់ការមិនប្រមាទ ។

# គប្បីរក្សាខ្លួនឲ្យល្អក្នុងវ័យទាំងបីរ

ព្រះសាស្តា ទ្រង់សំដែងបុព្វកម្មនេះ របស់ពោធិរាជកុមារនោះហើយ មានពុទ្ធដីកាត្រាស់ថា ម្នាលរាជកុមារ ក្នុងកាលនោះ បើព្រះអង្គ និងភរិយាមិនប្រមាទក្នុងវ័យណាមួយសោត, បុត្រ ឬធីតាគប្បីកើតឡើងក្នុងវ័យណាមួយ, បើអ្នកទាំងពីរសូម្បីតែ ម្នាក់ជាអ្នកមិនប្រមាទ, បុត្រ ឬធីតានឹងអាស្រ័យអ្នកដែលមិនប្រមាទនោះហើយ នឹងកើតឡើងបាន, ម្នាលរាជកុមារ បុគ្គលកាលបើសំគាល់ខ្លួនឯងថា ជាទីស្រឡាញ់ គប្បីមិនប្រមាទ រក្សាខ្លួនក្នុងវ័យទាំង ៣ បើមិនអាចរក្សា

បានដូច្នោះ គប្បីរក្សាឲ្យបានក្នុងវ័យណាមួយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

**១ អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

## អធិប្បាយគាថា

បណ្តាទាំងនោះ បទថា **យាមំ** នេះ ព្រះសាស្តា ទ្រង់សំដែងធ្វើវ័យទាំង ៣ វ័យណាមួយ ឲ្យឈ្មោះថា យាម ព្រោះព្រះអង្គទ្រង់ជាធំក្នុងធម៌ផង ព្រោះព្រះអង្គទ្រង់ឈ្លាសក្នុងវិធីទេសនាផង ហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្តីដូច្នេះថា បើបុគ្គលដឹងខ្លួនឯងថា ជាទីស្រឡាញ់ គប្បីរក្សាខ្លួននោះឲ្យល្អ គឺគប្បីរក្សាខ្លួននោះ ដោយប្រការដែលខ្លួនបានរក្សាល្អហើយ ។

បណ្តាជនអ្នករក្សាខ្លួននោះ បើអ្នកជាគ្រហស្ថគិតថា នឹងរក្សាខ្លួន ហើយចូលទៅក្នុងបន្ទប់ ដែលគេបិទបាំងយ៉ាងរៀបរយ ជាអ្នកមានការរក្សាសំបូរ នៅលើផ្ទៃប្រាសាទជាន់លើក្តី,

បើបព្វជិត នៅក្នុងលេនដ្ឋានដែលបិទបាំងយ៉ាងល្អ មានទ្វារ និង បង្អួចដែលបិទហើយក្តី ក៏មិនឈ្មោះថា រក្សាខ្លួនឡើយ ។ តែអ្នកជាគ្រហស្ថធ្វើបុណ្យទាំងឡាយ មានទានសីលជាដើម តាមកម្លាំងរបស់ខ្លួន, ឬជាបព្វជិតខ្វល់ខ្វាយក្នុងវត្ត បដិវត្ត បរិយត្តិ និងការធ្វើទុកក្នុងចិត្ត ឈ្មោះថា បានរក្សាខ្លួន ។

បុរសជាបណ្ឌិត កាលមិនអាចធ្វើបានយ៉ាងនោះ ក្នុងវ័យទាំង ៣ ត្រូវរក្សាខ្លួនទុកក្នុងវ័យណាមួយ ក៏បានដូចគ្នា ។ បើជាគ្រហស្ថ មិនអាចធ្វើកុសលបានក្នុងបឋមវ័យ ព្រោះរវល់នៅក្នុងការលេងសោត, ក្នុងមជ្ឈិមវ័យ គប្បីជាអ្នកមិនប្រមាទបំពេញកុសល ។ បើក្នុងមជ្ឈិមវ័យ រវល់ចិញ្ចឹមបុត្រ និងភរិយា មិនអាចបំពេញកុសលបានសោត, ក្នុងបច្ឆិមវ័យ គប្បីបំពេញកុសលឲ្យបាន ។ ដោយអាការយ៉ាងនេះឯង ខ្លួនទើបជាការដែលស្ងួនគ្រងល្អហើយដោយពិត ។ តែកាលមិនធ្វើដូច្នោះ ខ្លួនមិនឈ្មោះថា ជាទីស្រឡាញ់ឡើយ ។ អ្នកនោះ ប៉ុនគ្នានឹងធ្វើខ្លួនឲ្យមានឧបាយសំរាប់ទៅខាងមុខ ជាពិតប្រាកដ ។

បើបព្វជិត ក្នុងបឋមវ័យ ធ្វើការស្វាធ្យាយ ទ្រទ្រង់ចាំបង្រៀន ធ្វើវត្ត និងបដិវត្តន៍ ឈ្មោះថា ប្រមាទ, ក្នុងមជ្ឈិមវ័យ គប្បីជាអ្នកមិនប្រមាទបំពេញសមណធម៌ ។

ម្យ៉ាងទៀត បើរវល់សាកសួរការវិនិច្ឆ័យក្នុងអដ្ឋកថា និងហេតុនៃព្រះបរិយត្តិ ដែលខ្លួនរៀនហើយ ក្នុងបឋមវ័យ ឈ្មោះថា មានសេចក្តីប្រមាទ ក្នុងមជ្ឈិមវ័យ ។ ក្នុងបច្ឆិមវ័យ គប្បីជាអ្នកមិនប្រមាទ បំពេញសមណធម៌ចុះ ។ ដោយអាការយ៉ាងនេះឯង ខ្លួនជាការដែលបព្វជិតនោះ ស្លួនគ្រងល្អហើយ ។ តែបើមិនធ្វើដូច្នោះទេ ខ្លួនមិនឈ្មោះថា ជាទីស្រឡាញ់ ឡើយ, បព្វជិតនោះ ដូចគ្នានឹងធ្វើខ្លួនឲ្យក្តៅក្រហាយ ដោយការក្តៅក្រហាយក្នុងកាលជាខាងក្រោយ មែនពិត ។

ក្នុងកាលចប់ទេសនា ពោធិរាជកុមារតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនា បានសំរេចប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕៚

( រឿងពោធិរាជកុមារ ចប់ )

********************

# ២ រឿងព្រះឧបនន្ទសក្យបុត្រ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧបនន្ទសក្យបុត្រ ត្រាស់ព្រះធម្មទេសនានេះថា “**អត្តានមេវ បឋមំ**” ជាដើម ។

## ព្រះថេរៈចេញឧបាយរកលាភ

ដូចបានស្ដាប់មក ព្រះថេរៈនោះឆ្លាតពោលធម្មកថា ។ ភិក្ខុជាច្រើនរូបស្ដាប់ធម្មកថា ដែលបដិសំយុត្តដោយភាពជាអ្នកប្រាថ្នាតិចជាដើមរបស់លោកហើយ តែងបូជាលោកដោយចីវរទាំងឡាយ ហើយសមាទានធុតង្គ ។ ព្រះឧបនន្ទនោះប៉ុណ្ណោះ ទទួលយកបរិក្ខារដែលភិក្ខុទាំងនោះលះហើយ ។

វេជូវស្សាមួយជិតចូលមកដល់ ព្រះឧបនន្ទនោះបានចូលទៅកាន់ជនបទ លំដាប់នោះ សាមណេរ និងភិក្ខុក្នុងវត្តមួយពោល នឹងលោក ដោយការស្រឡាញ់ក្នុងធម្មកថិកថា លោកម្ចាស់ សូមលោកម្ចាស់ចាំវស្សាក្នុងទីនេះចុះ ។ ព្រះឧបនន្ទសួរថា ក្នុង វិហារនេះ

បានសំពត់ចំណាំវស្សាប៉ុន្មានផ្ទាំង កាលភិក្ខុទាំងនោះប្រាប់ថា បានសំពត់សាដកមួយអន្តមួយផ្ទាំង ក៏ដាក់ស្បែកជើងទុកក្នុងទីនោះ បានទៅកាន់ទីដទៃទៀត, ដល់វិហារទី ២ ហើយសួរថា ក្នុងវិហារនេះ ភិក្ខុទាំងឡាយបានអ្វីខ្លះ ? កាលពួកភិក្ខុប្រាប់ថា បានសំពត់ពីរផ្ទាំង ទើបដាក់ឈើប្រត់ទុក, ដល់វិហារទី ៣ សួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វីខ្លះ ? កាលភិក្ខុទាំងនោះប្រាប់ថា បានសំពត់ ៣ ផ្ទាំង ក៏ដាក់កំសៀវទឹកទុក, ដល់វិហារទី ៤ សួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វីខ្លះ ? កាលពួកភិក្ខុប្រាប់ថា បានសំពត់សាដក ៤ ផ្ទាំង ក៏ពោលថា ល្អណាស់ យើងនឹងនៅក្នុងទីនេះ ហើយក៏ចូលចាំវស្សាក្នុងវិហារនោះ ពោលធម្មកថាដល់គ្រហស្ថ និងភិក្ខុទាំងឡាយនោះឯង ។ គ្រហស្ថ និងភិក្ខុទាំងឡាយនោះ បូជាព្រះឧបនន្ទ ដោយសំពត់ និងចីវរជាច្រើនសន្ធឹក, ព្រះឧបនន្ទនោះ លុះចេញវស្សាហើយ បញ្ជូនដំណឹងទៅក្នុងវិហារដទៃទៀតថា“ យើងគួរបានសំពត់ចំណាំវស្សា ព្រោះយើងបានដាក់បរិក្ខារទុកដែរ, ភិក្ខុទាំងឡាយ ត្រូវបញ្ជូនសំពត់ចំណាំវស្សាឲ្យ

យើង" ឲ្យគេនាំសំពត់ ចំណាំវស្សាមកហើយ ផ្ទុកយានតូចបរចេញទៅ ។

## ព្រះឧបនន្ទៈកាត់ក្តីវិវាទ

គ្រានោះ ភិក្ខុកំឡោះ ២ រូបនៅក្នុងវិហារមួយ បានសំពត់ សាដក ២ ផ្ទាំង និងសំពត់កម្ពល ១ ផ្ទាំង មិនអាចនឹងចែកគ្នា បានថា សំពត់សាដកចូរជារបស់លោក, សំពត់កម្ពលជារប ស់ខ្ញុំ អង្គុយទាស់ទែងគ្នានៅជិតផ្លូវ ។ ភិក្ខុកំឡោះ ២ រូបនោះឃើញព្រះថេរៈនោះដើរមក ក៏ពោលថា សូមលោកម្ចាស់ជួយចែកឲ្យពួកខ្ញុំផង ។

ថេរៈ. ពួកលោកចូរចែកគ្នាចុះ ។

ភិក្ខុ. ពួកខ្ញុំមិនអាចទេ លោកម្ចាស់ សូមលោកម្ចាស់ជួយចែកឲ្យពួកខ្ញុំផង ។

ថេរៈ. ពួកលោកនឹងតាមពាក្យរបស់យើងឬ ?

ភិក្ខុ. លោកម្ចាស់ ពួកខ្ញុំនឹងតាម ។

ព្រះថេរៈនោះពោលថា បើដូច្នោះ ល្អហើយ ក៏ឲ្យសំពត់ សដក ២ ផ្ទាំងដល់ភិក្ខុកំលោះ ២ រូបនោះហើយ ពោលថា សំពត់កម្ពលនេះចូរជារបស់ខ្ញុំអ្នកពោលធម្មកថា

ហើយក៏កាន់

យកសំពត់កម្ពលដែលមានតំលៃច្រើនចៀសចេញទៅ ។ ពួកភិក្ខុកំឡោះបានក្តៅក្រហាយ ទៅកាន់សំណាក់ព្រះសាស្តា ក្រាបទូលរឿងនោះ ។

## បុព្វកម្មរបស់ព្រះឧបនន្ទ

ព្រះសាស្តា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទនេះកាន់យករបស់ពួកអ្នក ធ្វើឲ្យពួកអ្នកក្តៅក្រហាយមិនមែនតែឥឡូវនេះទេ សូម្បីកាលមុនធ្លាប់ធ្វើហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមកត្រាស់ថា ៖

ក្នុងអតីតកាល មានសត្វភេ ២ គឺភេរកស៊ីតាមមាត់ប្រាំងមួយ ភេរកស៊ីតាមទឹកជ្រៅមួយ បានត្រីធ្មិន ១ ធំ ឈ្លោះទាស់ទែងគ្នាថា ក្បាលចូរជារបស់យើង, កន្ទុយចូរជារបស់អ្នក, មិនអាចចែកគ្នាបាន ឃើញចចកមួយក៏ពោលថា លោកអ៊ំសូមលោកជួយចែកត្រីនេះឲ្យពួកខ្ញុំ ។

ចចក. យើងព្រះរាជា តាំងទុកក្នុងតំណែងនៃអ្នកប្រឹក្សា, យើងអង្គុយក្នុងទីវិនិច្ឆ័យនោះយូរហើយ ទើបចេញមកដើម្បីត្រាវការសំរាក, ឥឡូវនេះ យើងគ្មានឱកាសទេ ។

កេ. លោកអ៊ំ លោកកុំធ្វើយ៉ាងនេះឡើយ, មេត្តាជួយចែកឲ្យពួកខ្ញុំផង ។

ចចក. ពួកអ្នកនឹងធ្វើតាមពាក្យរបស់យើងឬ ?

កេ. ពួកខ្ញុំនឹងធ្វើតាម លោកអ៊ំ ។

ចចកនោះពោលថា បើដូច្នោះ ល្អហើយ ក៏បានកាត់ក្បាលទុកម្ខាង កាត់កន្ទុយទុកម្ខាង ក៏កាលកាត់ហើយពោលថា នែក្មួយទាំងពីរ ពួកអ្នកទាំងពីរ អ្នកណាត្រាច់តាមមាត់ច្រាំង អ្នកនោះត្រូវបានកន្ទុយ, អ្នកត្រាច់ទៅក្នុងទឹកជ្រៅ, ក្បាលត្រូវបានអ្នកនោះ, ចំណែកកណ្ដាលនេះ ត្រូវបានមកយើងដែលតាំងនៅក្នុងវិនិច្ឆ័យធម៌ កាលនឹងឲ្យកេទាំងពីរយល់ព្រម ទើបពោលគាថានេះថា ៖

កន្ទុយជារបស់កេ អ្នកត្រាច់រកស៊ីតាមមាត់ច្រាំង,
ក្បាលជារបស់កេ អ្នកត្រាច់រកស៊ីក្នុងទឹកជ្រៅ, ចំណែក
កណ្ដាលនេះ នឹងជារបស់យើង អ្នកតាំងនៅក្នុងធម៌ ។

រួចហើយក៏ពាំកំណាត់កណ្ដាលចៀសចេញទៅ ។ ចំណែកកេ

ទាំងពីរនោះក្តៅក្រហាយ បានឈរសំឡឹងមើលចចកនោះ ( ទាំងអាក់អន់ចិត្ត ) ។

ព្រះសាស្តាទ្រង់រឿងអតីតនេះហើយ មានពុទ្ធដីកាត្រាស់ថា សូម្បីក្នុងអតីតកាល ឧបនន្ទនេះក៏បានធ្វើឲ្យពួកអ្នកឲ្យក្តៅក្រហាយដែរ ឲ្យភិក្ខុទាំងនោះសុខចិត្តហើយ កាលនឹងទ្រង់តិះដៀលព្រះឧបនន្ទ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាអ្នកប្រៀនប្រដៅអ្នកដទៃ គប្បីធ្វើខ្លួនឲ្យតាំងនៅក្នុងគុណដ៏សមគួរមុនសិន ហើយបានត្រាស់ព្រះគាថានេះថា ៖

**២ អត្តានមេវ បឋមំ        បដិរូបេ និវេសយេ**

**អថញ្ញមនុសាសេយ្យ    ន កិលេសេយ្យ បណ្ឌិតោ ។**

បណ្ឌិតគួរតាំកល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ ( ធ្វើយ៉ាងនេះ ) នឹងមិនលំបាកឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទព្រះគាថាថា **បដិរូបេ និវេសយេ** បានដល់ គប្បីធ្វើខ្លួនឲ្យតាំងនៅក្នុងគុណដ៏សមគួរ, ព្រះសាស្តាត្រាស់ពាក្យនេះថា បុគ្គលណាបំណងនឹងប្រៀនប្រដៅអ្នកដទៃ

ដោយគុណ មានការប្រាថ្នាតិចជាដើម ឬដោយបដិបទារបស់ព្រះអរិយវង្សជាដើម, បុគ្គលនោះគប្បីធ្វើខ្លួននោះឯង ឲ្យតាំងនៅក្នុងគុណនោះជាមុនសិន, ពេលតាំងខ្លួនដូច្នោះហើយ គប្បីប្រៀនប្រដៅអ្នកដទៃដោយគុណនោះជាខាងក្រោយ ។ ព្រោះថាបុគ្គល កាលមិនញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះ ប្រដៅអ្នកដទៃតែម្តងនោះ តែងបានការនិន្ទាពីអ្នកដទៃ ឈ្មោះថារមែងលំបាក ។ បុគ្គលកាលញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះហើយប្រៀនប្រដៅអ្នកដទៃ រមែងបានការសរសើរអំពីអ្នកដទៃ, ព្រោះដូច្នោះ ឈ្មោះថា រមែងមិនលំបាកឡើយ ។ បណ្ឌិតកាលធ្វើយ៉ាងនេះ ឈ្មោះថា មិនគប្បីលំបាក ។

ក្នុងវេលាចប់ទេសនា ភិក្ខុទាំងពីររូបនោះ តាំងនៅក្នុងសោតាបត្តិផល ។ ធម្មទេសនាបានជាប្រយោជន៍ ដល់មហាជនដូច្នេះឯង ៕ល៚

( រឿងព្រះឧបនន្ទសក្យបុត្រ ចប់ )

***********************

# ៣ រឿងព្រះបធានិកតិស្សត្ថេរ

## សេចក្តីខាងដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រះបធានិកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**អត្តាន-ញ្ចេ**” ជាដើម ។*

## ព្រះបធានិកតិស្សត្ថេរល្អតែប្រដៅអ្នកដទៃ ខ្លួនឯងមិនធ្វើ

*ដូចបានស្តាប់មក ព្រះថេរៈនោះ រៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តាហើយ នាំពួកភិក្ខុប្រមាណ ៥០០ រូប ទៅចាំវស្សាក្នុងព្រៃ ពោលប្រដៅថា លោកមានអាយុទាំងឡាយ ពួកលោករៀនព្រះកម្មដ្ឋាន ក្នុងសំណាក់របស់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ព្រះជន្មនៅ, ត្រូវជាអ្នកមិនប្រមាទធ្វើសមណធម៌ចុះ ដូច្នេះហើយ ខ្លួនឯងក៏ទៅដេកលក់ ។ ភិក្ខុទាំងនោះចង្រ្កមក្នុងបឋមយាមហើយ ចូលទៅកាន់វិហារក្នុងមជ្ឈិមយាម ។ ព្រះថេរៈនោះ ទៅកាន់សំណាក់របស់ភិក្ខុទាំងនោះ ក្នុងវេលាខ្លួនដេកលក់ហើយភ្ញាក់ឡើង ពោលថា ពួកលោកមកដោយគិត*

ថា នឹងដេកលក់ដូច្នេះឬ ចូរប្រញាប់ទៅធ្វើសមណធម៌ចុះ ដូច្នេះហើយ ខ្លួនឯងក៏ទៅដេកយ៉ាងនោះនុ៎ះឯង ។ ពួកភិក្ខុក្រៅនេះចង្ក្រមនៅខាងក្រៅក្នុងមជ្ឈិមយាមហើយ ចូលទៅកាន់វិហារក្នុងបច្ឆិមយាម ។ ព្រះថេរៈនោះភ្ញាក់ឡើងម្តងទៀត ទៅកាន់សំណាក់របស់ភិក្ខុទាំងនោះ នាំភិក្ខុទាំងនោះចេញចាកវិហារហើយ ខ្លួនឯងក៏ទៅដេកលក់ទៀត, កាលព្រះថេរៈនោះធ្វើដូច្នោះរហូតកាលជានិច្ច, ភិក្ខុទាំងនោះ មិនអាចនឹងធ្វើការស្វាធ្យាយឬចំរើនព្រះកម្មដ្ឋានទុកក្នុងចិត្តបាន ក៏បានដល់ភាពជាអ្នកកាយមាយ ។ ភិក្ខុទាំងនោះប្រឹក្សាគ្នាថា អាចារ្យរបស់ពួកយើងប្រា-រព្ធសេចក្តីព្យាយាមខ្លាំងម៉្លេះ, ពួកយើងនឹងចាំឃ្លាំមើលលោក ពេលឃ្លាំចាំមើលលោក ឃើញកិរិយារបស់ព្រះថេរៈនោះ ក៏ពោលថា អ្នកមានអាយុទាំងឡាយ ពួកយើងវិនាសហើយ អាចារ្យរបស់ពួកយើងស្រែកទទេៗ បណ្តាភិក្ខុទាំងនោះ លំបាកពន់ពេក សូម្បីភិក្ខុមួយរូប ក៏មិនអាចញុំាងវិសេសឲ្យកើតឡើងបាន ។ ភិក្ខុទាំងនោះចេញវស្សាហើយ ទៅកាន់សំណាក់ព្រះសាស្តា មានបដិសណ្ឋារៈ ដែលព្រះសាស្តាទ្រង់ធ្វើហើយ ពេលទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ

ពួកអ្នកជាអ្នកមិន ប្រមាទ ធ្វើសមណធម៌ឬ ? ក៏នាំគ្នាក្រាបទូលរឿងនោះ ។

## រឿងមាន់រងាវមិនត្រូវវេលា

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះបាន ធ្វើអន្តរាយដល់ពួកអ្នក មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនោះក៏បានធ្វើអន្តរាយដល់ពួកអ្នកដែរ កាលភិក្ខុទាំងនោះទូលអង្វរហើយ ទ្រង់ក៏ញុំាងអកាលរវិកុក្កុដ ជាតកឲ្យពិស្តារ ( សេចក្តីសង្ខេប ) ថា ៖

មាន់នេះ ធំធាត់ហើយ ក្នុងសំណាក់របស់អ្នកមិន
មែនជាមាតាបិតា នៅក្នុងត្រកូលមួយមិនមែនជាអាចារ្យ
ទើបមិនដឹងកាល ឬមិនមែនកាល ។

ដូច្នេះហើយ ទ្រង់មានពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុ កាលប្រៀនប្រដៅអ្នកដទៃ គប្បីធ្វើខ្លួនឯងឲ្យជាការ ទូន្មានល្អហើយសិន, ព្រោះបុគ្គល ជាអ្នកទូន្មានខ្លួនល្អហើយ កាលទូន្មានគេឈ្មោះថា រមែងទូន្មានអ្នកបាន ហើយត្រាស់ ព្រះគាថានេះថា ៖

**៣ អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ**

**សុទន្តោ វត ទមេថ  អត្តា ហិ កិរ ទុទ្ទមោ ។**

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឯងឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

# អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានេះថា ៖

ភិក្ខុពោលថា គប្បីចង្រ្កមក្នុងបឋមយាមជាដើម ឈ្មោះថា ពោលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ខ្លួនឯងក៏ដូច្នោះ ត្រូវអធិដ្ឋានកិច្ច មានចង្រ្កមជាដើម ទើបឈ្មោះថា ធ្វើខ្លួនឯងដូចទូន្មានអ្នកដទៃ ។ កាលបើដូច្នេះ ភិក្ខុនោះជាអ្នកមានខ្លួនទូន្មានល្អហើយ គួរទូន្មានបុគ្គលដទៃបាន ។

បាទព្រះគាថាថា **សុទន្តោ វត ទមេថ** សេចក្តីថា ភិក្ខុប្រៀនប្រដៅអ្នកដទៃដោយគុណណា, ត្រូវជាអ្នកហ្វឹកហាត់ល្អហើយ ដោយខ្លួនឯង ដោយគុណនោះសិន ទើបគួរទូន្មានអ្នកដទៃ ។

បាទព្រះគាថា **អត្តា ហិ កិរ ទុទ្ទមោ** សេចក្ដីថា ព្រោះថា ខ្លួននេះ ជាសភាពដែលបុគ្គលទូន្មានបានដោយក្រ, ព្រោះហេតុនោះ ខ្លួននោះ ជាសភាពដែលបុគ្គលទូន្មានល្អហើយដោយ ប្រការណា គួរទូន្មានខ្លួនដោយប្រការនោះ ។

ក្នុងវេលាចប់ទេសនា ភិក្ខុប្រមាណ ៥០០ រូបនោះបានសំរេចព្រះអរហត្តផល ដូច្នេះឯង ៕

( រឿងព្រះបធានិកតិស្សត្ថេរ ចប់ )

************************

# ៤ រឿងមាតារបស់ព្រះកុមារកស្សបត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតារបស់ព្រះកុមារកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា *“**អត្តា ហិ អត្តនោ នាថោ**”* ជាដើម ។

## មាតារបស់ព្រះកុមារកស្សបៈបួស

បានឮថា មាតារបស់ព្រះថេរៈនោះ ជាសេដ្ឋីធីតា ក្នុងក្រុងរាជគ្រឹះ បានសូមបព្វជ្ជា តាំងអំពីខ្លួនទើបនឹងដឹងក្តី,តែទោះខំអង្វររឿយៗ ក៏មាតា និងបិតាមិនឲ្យបព្វជ្ជា ចំរើនវ័យហើយទៅកាន់ត្រកូលស្វាមី ជាអ្នកមានស្វាមីដូចជាទេវតា នៅគ្រប់គ្រងផ្ទះ ។ កាលតមក មិនយូរប៉ុន្មាន នាងក៏មានគភ៌, តែនាងមិនដឹងថាខ្លួនមានគភ៌ឡើយ ញ៉ាំងស្វាមីឲ្យត្រេកអរហើយ ក៏បានសូមបព្វជ្ជា ។ គ្រានោះ ស្វាមីនាំនាងទៅកាន់សំណាក់នាងភិក្ខុនីដោយសក្ការៈដ៏ធំ មិនដឹងក៏ឲ្យបួសក្នុងសំណាក់ភិក្ខុនី ដែលជាបក្ខពួករបស់ទេវទត្ត ។

សម័យក្រោយមក នាងត្រូវពួកភិក្ខុនីនោះ ដឹងថា មានគភ៌ហើយ សួរថា នេះដូចម្ដេចហ្ន៎ ? ក៏ប្រាប់ថា ម៉ែម្ចាស់ នាងខ្ញុំមិនជ្រាបថា នេះដូចម្ដេចទេ តែសីលរបស់នាងខ្ញុំ មិនបានធ្លុះធ្លាយឡើយ ។ ពួកនាងភិក្ខុនី នាំនាងទៅកាន់សំណាក់ទេវទត្តហើយ សួរថា នាងភិក្ខុនីនេះបួសដោយសទ្ធា, ពួកខ្ញុំមិនជ្រាបថានាងមានគភ៌, ឥឡូវនេះ ពួកខ្ញុំនឹងធ្វើដូចម្ដេច ? ព្រះទេវទត្តគិតហេតុត្រឹមតែប៉ុណ្ណោះថា សេចក្ដីអាប់ឱន ចូរកុំកើតឡើងដល់ពួកភិក្ខុនីអ្នកធ្វើតាមឱវាទយើង ក៏ពោលថា ពួកនាងចូរឲ្យនាងនោះសឹកចេញទៅ ។ ភិក្ខុនីក្រមុំនោះ ស្ដាប់ពាក្យនោះហើយពោលថា នាងម្ចាស់ សូមនាងម្ចាស់ទាំងឡាយ កុំឲ្យខ្ញុំវិនាសឡើយ, ខ្ញុំមិនបានបួសឧទ្ទិសព្រះទេវទត្តទេ, នាងម្ចាស់ទាំង-ឡាយចូរមកចុះ ចូរនាំខ្ញុំទៅកាន់វត្តជេតពន ដែលជាសំណាក់ព្រះសាស្ដា ។ នាងភិក្ខុនីទាំងនោះ នាំនាងទៅកាន់វត្តជេតពនហើយក្រាបទូលដល់ព្រះសាស្ដា ។

## ព្រះកុមារកស្សបៈកើត

ព្រះសាស្ដា សូម្បីទ្រង់ជ្រាបថា នាងមានគភ៌តាំងអំពីនៅជាគ្រហស្ថ តែដើម្បីដោះស្រាយវាទៈជនដទៃ ទើប

ទ្រង់ឲ្យព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិក មហាឧបាសិកាវិសាខា និងត្រកូលធំៗ ដទៃទៀតមកហើយ ទ្រង់បង្គាប់ព្រះឧបលិត្ថេរថា អ្នកចូរទៅ, ចូរជំរះកម្មរបស់ភិក្ខុក្រមុំនេះឲ្យល្អ កណ្តាលបរស័ទទាំង ៤ ។ ព្រះថេរៈឲ្យគេអញ្ជើញនាងវិសាខា មុខព្រះភក្ត្រព្រះរាជាហើយ ឲ្យសំរុះសំរួលអធិករណ៍នោះ ។ នាងវិសាខា ឲ្យមនុស្សព័ទ្ធគ្រឿងបិទបាំងគឺរាំងននពិនិត្យមើលដៃ ជើង ផ្ចិត និងទីបំផុតនៃផ្ទៃរបស់នាងភិក្ខុនីនោះខាងក្នុងរាំងនន ហើយរាប់ខែ និងថ្ងៃទៅដឹងថា នាងមានគភ៌កាលនៅជាគ្រហស្ថម្ល៉េះ ទើបប្រាប់សេចក្តីនោះដល់ព្រះថេរៈ, គ្រានោះ ព្រះថេរៈញុំាងភាវៈដែលនាងជាអ្នកបរិសុទ្ធ ឲ្យត្រឡប់តាំងឡើងនៅកណ្តាលបរិស័ទ ។ ដោយសម័យដទៃទៀត នាងបានប្រសូតបុត្រ មានអានុភាពច្រើនដែលមានការប្រាថ្នាតាំងទុក ទៀបបាទមូលរបស់ព្រះពុទ្ធជាម្ចាស់ ព្រះនាមថា បទុមុត្តរៈ ។

ក្រោយមក ថ្ងៃមួយ ព្រះរាជា ស្តេចទៅទីជិតសំណាក់របស់នាងភិក្ខុនី ទ្រង់សណ្តាប់សំឡេងទារក ត្រាស់សួរថា នេះសំឡេងអ្វី កាលអាមាត្យក្រាបទូលថា ព្រះអង្គ បុត្ររបស់នាង

កិក្ខុនីនោះកើត, ទុំះជាសំឡេងបុត្ររបស់នាងកិក្ខុនីនោះ, ទ្រង់នាំកុមារនោះ ទៅកាន់ព្រះរាជមន្ទីររបស់ព្រះអង្គ បានប្រទានឲ្យដល់មេដោះទាំងឡាយ ។ ក៏ក្នុងថ្ងៃដាក់ឈ្មោះ ជនទាំងឡាយដាក់ឈ្មោះកុមារនោះថា កស្សបៈ តែចំណាំបានថា កុមារក-ស្សបៈ ព្រោះកុមារនោះ ជាអ្នកដែលព្រះរាជាឲ្យចំរើនហើយដោយគ្រឿងរក្សារបស់កុមារ ។ កុមារនោះវាយក្មេងក្នុងទីលានកីឡា, កាលពួកក្មេងពោលថា ពួកយើងត្រូវមនុស្សមិនមានម៉ែឪវាយ, ទើបចូលទៅគាល់ព្រះរាជា ទូលសួរថា បពិត្រព្រះអង្គទ្រង់ជាសម្មតិទេព ពួកក្មេងពោលនឹងខ្ញុំព្រះអង្គថា មិនមានមាតា និងបិតា, សូមព្រះអង្គ ត្រាស់ប្រាប់មាតាដល់ខ្ញុំព្រះអង្គ, ព្រះរាជាទ្រង់បង្ហាញស្ត្រីមេដោះទាំងឡាយហើយ ត្រាស់ប្រាប់ថា ស្ត្រីទាំងនេះជាមាតារបស់អ្នក ក៏ក្រាបទូលថា មាតារបស់ខ្ញុំព្រះអង្គមិនមានប៉ុណ្ណេះទេ, មាតាខ្ញុំព្រះអង្គមានតែមួយប៉ុណ្ណោះ, សូមព្រះអង្គត្រាស់ប្រាប់មាតានោះដល់ខ្ញុំព្រះអង្គចុះ ។ ព្រះរាជា ទ្រង់ព្រះចិន្តាថា យើងមិនអាចបញ្ឆោតកុមារនេះបាន ទើបប្រាប់ ថា នែអ្នក

មាតារបស់អ្នកជាភិក្ខុនី អ្នក គឺយើងនាំមកអំពីសំណាក់របស់នាងភិក្ខុនី ។

## កុមារកស្សបៈចេញបួសសំរេចព្រះអរហត្ត

កុមារនោះ មានសេចក្ដីសង្វេគកើតឡើងហើយ ដោយហេតុត្រឹមប៉ុណ្ណោះនុះឯង ក្រាបទូលថា "បពិត្រព្រះបិតា សូមព្រះអង្គទ្រង់ឲ្យទូលបង្គំបួសចុះ" ព្រះរាជាទ្រង់ទទួលថា "ល្អៗបុត្រ" ហើយឲ្យកុមារនោះបួសក្នុងសំណាក់ព្រះសាស្ដា ដោយសក្ការៈជាច្រើន ។

កុមារកស្សបៈនោះ បានឧបសម្បទាហើយ ប្រាកដនាមថា ព្រះកុមារកស្សបត្ថេរ ។ លោករៀនកម្មដ្ឋានទៅក្នុងសំណាក់ព្រះសាស្ដា ចូលទៅកាន់ព្រៃព្យាយាម មិនអាចនឹងញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ទើបគិតថា យើងនឹងរៀនកម្មដ្ឋានឲ្យវិសេសឡើង មកកាន់សំណាក់ព្រះសាស្ដា នៅក្នុងព្រៃអន្ធវ័នហើយ, គ្រានោះ ភិក្ខុអ្នកធ្វើសមណធម៌រួមគ្នា ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបៈ សំរេចអនាគាមិផលហើយ កើតក្នុងព្រហ្មលោកមកអំពីព្រហ្មលោក សួរបញ្ហា ១៥ ខ នឹងព្រះកុមារកស្សបៈនោះហើយបញ្ជូនទៅដោយពាក្យថា អ្នកដទៃវៀរព្រះ

សាស្តាចេញហើយ ដែលអាចនឹងព្យាករណ៍បញ្ហាទាំងនេះមិនមានទេ ។ លោកចូរទៅ, ចូររៀនសេចក្ដីនៃបញ្ហាទាំងនេះក្នុងសំណាក់ព្រះសាស្ដាចុះ ។ លោកបានធ្វើដូច្នោះ ក៏សំរេចព្រះអរហត្ត ក្នុងវេលាដែលព្រះសាស្ដា ទ្រង់ឆ្លើយបញ្ហាចប់ ។

## មាតារបស់ព្រះកុមារកស្សបៈសំរេចព្រះអរហត្ត

ក៏តាំងអំពីថ្ងៃ ដែលព្រះថេរៈនោះចេញទៅហើយ ទឹកភ្នែកហូរចេញចាកនេត្រទាំងពីររបស់នាងភិក្ខុនី ដែលជាមាតាអស់ ១២ ឆ្នាំ ។ នាងមានទុក្ខព្រោះប្រាត់ប្រាសចាកបុត្រ (ដូចប្ដីប្រពន្ធព្រាត់ប្រាសគ្នាដូច្នោះដែរ) មានមុខជោកដោយទឹកភ្នែកជានិច្ច ត្រាច់ទៅដើម្បីភិក្ខា គ្រាន់តែឃើញព្រះថេរៈក្នុងចន្លោះផ្លូវ ក៏ស្រែកឡើងថា កូនៗ ស្ទុះចូលទៅដើម្បីនឹងចាប់ព្រះថេរៈក៏បានដួលចុះ ។ នាងមានដោះហូរទឹកដោះចេញ ក្រោកឡើងមានចីវរសើម ទៅចាប់ព្រះថេរៈ ។ ព្រះថេរៈគិតថា បើមាតានេះ បានពាក្យផ្អែមពីរោះអំពីសំណាក់របស់យើង, នាងនឹងវិនាស, យើងនឹងចរបាទីងមាតានេះ ដោយពាក្យទ្រគោះ ។ ខណៈនោះ ព្រះថេរៈពោលនឹងនាងភិក្ខុនី ដែលជាមាតានោះថា នាងត្រាច់ធ្វើអ្វី មិនអាចកាត់ត្រឹមតែសេចក្ដីស្រឡាញ់បាន

នាង គិតថា ឱ ! ពាក្យរបស់ព្រះថេរៈគ្រោតគ្រាត កូនៗ និយាយ អ្វី ? ត្រូវព្រះថេរៈថាឲ្យជួប្រោះទៀត ទើបគិតថា យើងមិនអាច ទប់ទឹកភ្នែកបានអស់ ១២ ឆ្នាំ ព្រោះហេតុតែបុត្រនេះ, តែបុត្រ របស់យើងនេះ មានចិត្តរឹងត្អឹង, ប្រយោជន៍អ្វី សំរាប់យើង ដោយបុត្រនេះ កាត់សេចក្តីស្នេហាក្នុងបុត្របានហើយ ក៏សំរេច ព្រះអរហត្តក្នុងថ្ងៃនោះឯង ។

## ពួកភិក្ខុនាំគ្នាសរសើរព្រះពុទ្ធគុណ

សម័យក្រោយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ព្រះកុមារកស្សបត្ថេរ និងព្រះថេរី ជាអ្នកសម្បូណ៌ដោយឧបនិស្ស័យយ៉ាងនេះ ត្រូវព្រះទេវទត្តឲ្យវិនាសហើយ ចំណែកព្រះសាស្តា ទ្រង់ជាទីពឹងរបស់អ្នកទាំងពីរនោះ, ឱ ! អស្ចារ្យណាស់ ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់ជាអ្នកអនុគ្រោះលោក ។

ព្រះសាស្តា ស្តេចមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ? ភិក្ខុទាំងនោះ ក្រាបទូលថា ដោយរឿងឈ្មោះនេះ ទ្រង់ក៏ត្រាស់

ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ច័យ ជាទីពំនាក់របស់អ្នកទាំងពីរនេះ មិនមែនតែឥឡូវនេះទេ ក្នុងកាលមុនតថាគតក៏បានជាទីពំនាក់របស់អ្នកទាំងពីរនោះដែរ ហើយទ្រង់ត្រាស់និគ្រោធជាតកនេះ ដោយពិស្ដារថា ៖

អ្នក ឬអ្នកដទៃ គប្បីគប់ម្រឹគឈ្មោះនិគ្រោធតែម្យ៉ាង កុំចូលទៅគប់រកម្រឹគឈ្មោះសាខៈឡើយ, ការស្លាប់ក្នុងសំណាក់របស់ម្រឹគឈ្មោះនិគ្រោធប្រសើរជាង, ការរស់នៅក្នុងសំណាក់របស់ម្រឹគឈ្មោះសាខៈនោះ មិនប្រសើរឡើយ ។

ទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះសាខៈក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ, សូម្បីបរិស័ទរបស់ម្រឹគឈ្មោះសាខៈនោះ ក៏បានជាបរិស័ទរបស់ទេវទត្តនោះឯង, មេម្រឹគដែលដល់វារៈ បានជាព្រះថេរី, កូនម្រឹគបានជាកុមារកស្សបៈ ចំណែកស្ដេចម្រឹគឈ្មោះថា និគ្រោធ ដែលទៅលះបង់ជីវិតដល់មេម្រឹគមានគភ៌ គឺតថាគត, ទ្រង់ប្រកាសភាពដែលព្រះ-ថេរីកាត់សេចក្ដីស្រឡាញ់ក្នុងបុត្រហើយ ធ្វើទីពឹងដល់ខ្លួនឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលអាស្រ័យមនុស្ស

ដទៃ មិនអាចដើម្បីនឹងមានសួគ៌ ឬមគ្គសំរាប់ទៅបរលោកបាន ទេ, ដូច្នោះ ខ្លួននោះឯងជាទីពឹងរបស់ខ្លួន, មនុស្សដទៃទនឹងធ្វើអ្វី បាន ហើយត្រាស់ព្រះគាថានេះថា ៖

៤ អត្តា ហិ អត្តនោ នាថោ   កោ ហិ នាថោ បរោ សិយា
  អត្តនា ហិ សុទន្តេន   នាថំ លភតិ ទុល្លភំ

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន
ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាន
នូវទីពឹង ដែលគេបានដោយកម្រ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **នាថោ** គឺជាទីពំនាក់ ព្រះ-មានព្រះភាគត្រាស់ពាក្យនេះទុកថា បុគ្គលស្ថិតនៅក្នុងខ្លួន គឺ សម្បូណ៌ដោយខ្លួន អាចធ្វើកុសលហើយដល់សួគ៌ ឬដើម្បី ញុំាំងមគ្គឲ្យចំរើន ឬធ្វើឲ្យជាក់ច្បាស់នូវផលបាន, ព្រោះហេតុ នោះឯង ខ្លួនឯងទើបជាទីពឹងរបស់ខ្លួន អ្នកដទៃណាសោត គប្បីជាទីពឹងរបស់បុគ្គលដទៃបាន, ព្រោះបុគ្គលមានខ្លួនហ្វឹកល្អ ហើយ គឺមិនមានការសេពគប់ខុស រមែងបានទីពឹងដែល គេបានដោយកម្រ ពោលគឺអរហត្តផល ។ ក៏ពាក្យថា **នាថំ**

**លកតិ ទុល្ហកំ** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកព្រះ-អរហត្ត ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនទាក់សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

( រឿងមាតារបស់ព្រះកុមារកស្សបៈ ចប់ )

******************************

# ៥ រឿងឧបាសកឈ្មោះមហាកាល

## សេចក្ដីខាងដើម

ព្រះសាស្ដា គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកជាព្រះសោតាបន្នម្នាក់ ឈ្មោះមហាកាល ត្រាស់ព្រះធម្មទេសនានេះថា “**អត្តនា ហិ កតំ បាបំ**” ជាដើម ។

## មហាកាលត្រូវចោទថាជាចោរត្រូវគេវាយស្លាប់

បានឮថា ឧបាសកនោះជាអ្នករក្សាឧបោសថ ៨ ថ្ងៃ នៃខែ ( មួយខែ ៨ ថ្ងៃ ) ស្ដាប់ធម្មកថារហូតពេញមួយយប់ក្នុងវិហារ ។ គ្រានោះ ពួកចោរកាត់ទីតក្នុងផ្ទះមួយក្នុងវេលាយប់ កាន់យកបង្វេចកណ្ដុះទៅ ត្រូវពួកម្ចាស់របស់ភ្ញាក់ឡើង ព្រោះសំឡេងភាជនៈលោហៈទង្គិចគ្នា ដេញតាមហើយ ទម្លាក់ចោលរបស់ដែលខ្លួនកាន់យក ហើយក៏រត់គេចចេញទៅ ។

ចំណែកពួកម្ចាស់របស់ ជាប់តាមចោរជានិច្ច ។ ពួកចោរទាំងនោះខ្ចាត់ខ្ចាយគ្នាទៅគ្រប់ទិស ។ ចំណែកចោរម្នាក់កាន់យកផ្លូវទៅកាន់វិហារ ទម្លាក់បង្វេចកណ្ដុះទុកខាងមុខមហា

កាល អ្នកស្ដាប់ធម្មកថាវេហួតពេញមួយយប់ លប់លាងមុខជិត មាត់ព្រះបោក្ខរណីអំព្រលឹមហើយ រត់ចេញទៅ ។

ពួកមនុស្សជាប់តាមពួកចោរមក ឃើញបង្វេចភណ្ឌៈហើយ ក៏ចាប់មហាកាលនោះ ដោយពោលថា ឯងកាត់ទីតក្នុងផ្ទះរបស់ពួកយើង លួចយកបង្វេចភណ្ឌៈទៅហើយ មកធ្វើដូចជាស្ដាប់ធម៌ បានវាយដំគាត់ឲ្យស្លាប់ ហើយក៏ចៀសចេញទៅ ។

## មហាកាលស្លាប់សមគួរដល់បុព្វកម្ម

គ្រានោះ ភិក្ខុកំលោះ និងពួកសាមណេរទាំងឡាយ កាន់ក្អមទឹកទៅអំពីព្រលឹម ជួបមហាកាលនោះ ពោលថា ឧបាសកស្ដាប់ធម្មកថានៅក្នុងវិហារ បានមរណៈមិនសមគួរ ហើយក៏នាំគ្នាក្រាបទូលដល់ព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាកាលបានមរណៈមិនសមគួរក្នុងអត្តភាពនេះពិតមែនហើយ, តែគេបានមរណៈសមគួរដល់កម្មដែលធ្វើទុកហើយក្នុងកាលមុននោះឯង ភិក្ខុកំលោះ និងសាមណេរទាំងនោះអារាធនាហើយ ទ្រង់ក៏ត្រាស់បុព្វកម្មរបស់មហាកាលនោះថា ៖

បុព្វកម្មរបស់មហាកាល

បានឮថា ក្នុងអតីតកាល មានពួកចោរនៅចាំស្ទាក់ត្រង់មាត់ព្រៃ នៃបច្ចន្តគ្រាមមួយកន្លែង ក្នុងដែននៃព្រះចៅពារាណសី ។ ព្រះរាជាទ្រង់ចាត់តាំងរាជភដម្នាក់ទុកត្រង់មាត់ព្រៃ ។ រាជភដនោះ ទទួលថ្លៃឈ្នួលហើយ ក៏នាំមនុស្សទៅអំពីត្រើយខាងនេះទៅកាន់ត្រើយខាងនោះ, នាំមនុស្សអំពីត្រើយខាងនោះមកកាន់ត្រើយខាងនេះ ។

តមកមនុស្សម្នាក់ នាំភរិយារូបស្អាតរបស់ខ្លួនឡើងកាន់យានតូចហើយ បានទៅដល់ទីនោះ ។ រាជភដគ្រាន់តែឃើញស្ត្រីនោះ ក៏កើតស្នេហា, កាលមនុស្សនោះពោលថា នាយសូមលោកជួយនាំខ្ញុំទាំងពីរឲ្យឆ្លងផុតព្រៃផង ក៏ប្រាប់ថា ឥឡូវនេះយប់ហើយ, ចាំព្រឹកចុះ យើងនឹងជួយឲ្យឆ្លងផុតទៅ ។

មនុស្ស. នាយ នៅទាន់វេលាទេ, មេត្តានាំខ្ញុំទាំងពីរទៅឥឡូវនេះចុះ ។

រាជភដ. ត្រឡប់ចុះ អ្នកដ៏ចំរើន អាហារ និងទីស្នាក់អាស្រ័យក្នុងផ្ទះរបស់ខ្ញុំមាន ។

មនុស្សនោះមិនប្រាថ្នានឹងត្រឡប់ឡើយ ។ ចំណែករាជ-កជនេះ ឲ្យសញ្ញាដល់ពួកបុរស ញាំងយានតូចឲ្យត្រឡប់ហើយ ឲ្យទីស្នាក់អាស្រ័យត្រង់ខ្លោងទ្វារ ឲ្យគេរៀបចំអាហារដល់មនុស្សនោះ ទាំងដែលមិនប្រាថ្នាឡើយ ។ ក៏ក្នុងផ្ទះរាជកជនោះ មាន កែវមណីមួយ ។ រាជកជនោះឲ្យគេយកកែវមណីទៅលាក់ទុក

ក្នុងចន្លោះនៃយានតូចរបស់មនុស្សនោះហើយ ក្នុងវេលាជិតភ្លឺក៏ធ្វើសំឡេងដូចជាពួកចោរចូលស្រុក ។

លំដាប់នោះ ពួកបុរសបង្ហាញដល់រាជកជថា នាយ កែវមណី ត្រូវពួកចោរលួចយកទៅហើយ ។ រាជកជបញ្ជាថា ពួកអ្នកចូរតាំងកងរក្សាទុកត្រង់ទ្វារស្រុកទាំងឡាយ ពិនិត្យមើលអ្នកចេញទៅអំពីខាងក្នុងស្រុក ។ ចំណែកមនុស្សក្រៅនេះ រៀបចំយានតូចស្រេចហើយ ក៏បរចេញទៅពីព្រលឹម ។ ខណៈនោះពួកអ្នកបំរើរបស់រាជកជ ក៏ឆែកឆេរយានតូចរបស់មនុស្សនោះឃើញកែវមណី ដែលខ្លួនលាក់ទុក ក៏គំរាមថា អ្នកលួចយកកែវមណីទៅ ក៏វាយបង្ហាញដល់មេស្រុកថា នាយ ពួកខ្ញុំចាប់ចោរបានហើយ ។ មេស្រុកនិយាយថា យើងជារាជកជ ឲ្យ

អ្នកស្នាក់អាស្រ័យក្នុងផ្ទះ ឲ្យកត្តហើយ
ឯងហ៊ានលួចយកកែវ-មណី

ពួកអ្នកចូរចាប់អាបុរសអាក្រក់នេះ ហើយឲ្យនាំគ្នាវាយដំទាល់តែស្លាប់ ។ នេះជាបុព្វកម្មរបស់មហាកាលនោះ ។ រាជកដនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងអវិចី ឆេះក្នុងអវីចីនោះអស់កាលដ៏យូរ ត្រូវគេវាយដំដល់មរណភាពយ៉ាងនោះឯង អស់ ១០០ អត្តភាព ព្រោះវិបាកដែលសេសសល់ ។

## បាបរមែងញាំញីអ្នកធ្វើ

ព្រះសាស្តា សំដែងបុព្វកម្មរបស់មហាកាលនោះហើយ មានព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាបកម្មដែលខ្លួនធ្វើទុកនោះឯង រមែងញាំញីសត្វទាំងនេះ ក្នុងអបាយទាំង ៤ ហើយត្រាស់ព្រះគាថានេះថា ៖

**៥ អត្តនា ហិ កតំ បាបំ អត្រជំ អត្តសម្ភវំ**
**អភិមត្ថតិ ទុម្មេធំ វជិរំវម្ហយំ មណឹ ។**

បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួន
ធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រ
សំរាប់កាត់កែវមណី ដែលកើតអំពីថ្មដូច្នោះឯង ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **វជិរំវម្ហយំ មណឹ** សេចក្ដីថា ដូចជាពេជ្រសំរាប់កាត់កែវមណី ដែលកើតអំពីថ្ម ។ លោកអធិប្បាយពាក្យនេះទុកថា ពេជ្រដែលសំរេចអំពីថ្ម មានថ្មជាដែនកើត កាត់កែវមណីដែលកើតអំពីថ្ម គឺកែវមណីដែលសំរេចអំពីថ្ម ដែលរាប់ថាជាទីតាំងរបស់ខ្លួននោះនុ៎ះឯង គឺធ្វើឲ្យជាប្រហោងតូច-ធំ ឲ្យជាកំណាត់តូច-ធំ ធ្វើឲ្យប្រើប្រាស់មិនបាន យ៉ាងណា, បាបដែលខ្លួនធ្វើហើយ កើតក្នុងខ្លួន មានខ្លួនជាដែនកើត រមែងញាំញី គឺកំចាត់បុគ្គលអ្នកមានបញ្ញាតិច គឺអ្នកឥតបញ្ញា ក្នុងអបាយ ៤ ដូច្នោះឯង ។

ក្នុងវេលាចប់ទេសនា ភិក្ខុដែលមកប្រជុំគ្នា សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផល ដូច្នេះឯង ៕

( រឿងឧបាសកឈ្មោះមហាកាល ចប់ )

****************************

# ៦ រឿងព្រះទេវទត្ត

## សេចក្ដីខាងដើម

ព្រះសាស្ដា គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះ-ទេវទត្ត ត្រាស់ព្រះធម្មទេសនានេះថា “**យស្ស អច្ចន្តទុស្សីល្យំ**” ជាដើម ។

## សន្ទនារឿងលាមករបស់ទេវទត្ត

សេចក្ដីពិស្ដារថា ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្ម-សភាថា អ្នកមានអាយុទាំងឡាយ ទេវទត្តជាអ្នកទ្រុស្ដសីល មានធម៌លាមក ញុះញង់ព្រះបាទអជាតសត្រូវ ញ៉ាំងលាភនិងសក្ការៈជាច្រើនឲ្យកើតឡើង បបួលព្រះបាទអជាតសត្រូវក្នុងការសំលាប់ព្រះរាជបិតា ព្យាយាមដើម្បីនឹងសំលាប់ព្រះ-តថាគត ដោយប្រការផ្សេងៗ ព្រោះតណ្ហា ដែលចំរើនឡើងហើយ ដោយហេតុគឺភាពជាអ្នកទ្រុស្ដសីលនោះឯង ។

ព្រះសាស្ដា ស្ដេចមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាអ្វី ? ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គចំរើន ពួកខ្ញុំព្រះអង្គសន្ទនាគ្នា

ដោយកថានេះ ទ្រង់ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ, ក្នុងកាលមុនទេវទត្តក៏ព្យាយាមដើម្បីសំលាប់តថាគត ដោយប្រការផ្សេងៗ ដែរ ត្រាស់ព្រះជាតកទាំងឡាយ មានកុរុង្គជាតកជាដើមហើយ ទ្រង់មានព្រះពុទ្ធ-ដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហា ដែលកើតឡើងព្រោះហេតុ គឺជាអ្នកទ្រុស្តសីល រុំព័ទ្ធ រួបរឹតនូវបុគ្គលទ្រុស្ត-សីលក្រែកន្ទង់ ទៅក្នុងអបាយ មាននរកជាដើម ដូចជាពួរជ្រៃរួបរឹតដើមឈើ ហើយបំបាក់ចុះដូច្នោះ ហើយត្រាស់ព្រះគាថានេះថា ៖

**៦ យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ**
**ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។**

ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ ( នូវអត្តភាព ) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាស ដូច្នោះ ។

## អធិប្បាយគាថា

ភាពជាអ្នកទ្រុស្តសីលដោយចំណែកតែមួយ ឈ្មោះថា **អច្ចន្តទុស្សីល្យំ** ក្នុងព្រះគាថានោះ ។ បុគ្គលជាគ្រហស្ថ ធ្វើអកុសលកម្មបថ ១០ តាំងអំពីកើតក្តី, អ្នកជាបព្វជិតត្រូវគរុកាបត្តិ គឺបារាជិក និងសង្ឃាទិសេស តាំងអំពីថ្ងៃឧបសម្បទាមកក្តី ឈ្មោះថា អ្នកទ្រុស្តសីលហួសហេតុ ។

តែបទថា **អច្ចន្តទុស្សីល្យំ** នេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ក្នុងព្រះគាថានេះ ទ្រង់សំដៅយកភាពជាអ្នកទ្រុស្តសីលដែលមកហើយតាមគតិរបស់បុគ្គលអ្នកទ្រុស្តសីល ២-៣ អត្តភាព ។

ម្យ៉ាងទៀត តណ្ហាដែលអាស្រ័យទ្វារ ៦ របស់បុគ្គលទ្រុស្តសីលកើតឡើង បណ្ឌិតគប្បីជ្រាបថា ភាពជាអ្នកទ្រុស្តសីលក្នុងព្រះគាថានេះ ។

បាទព្រះគាថាថា **មាលុវា សាលមិវោត្ថតំ** សេចក្តីថា ភាពជាអ្នកទ្រុស្តសីល ពោលគឺតណ្ហា រួបរឹត គឺគ្របសង្កត់អត្តភាពរបស់បុគ្គលណា, ដូចជាពួរជ្រៃរួបរឹតដើមឈើ គឺគ្របដណ្តប់សព្វអន្លើ ដោយអំណាចការទទួលទឹកដោយស្ទឹក ក្នុងពេលភ្លៀងធ្លាក់ ហើយបំបាក់ចុះដូច្នោះឯង ។បុគ្គលនោះ គឺអ្នក

ត្រូវតណ្ហា ពោលគឺភាពជាអ្នកទ្រុស្តសីលនោះ គ្របសង្កត់ឲ្យធ្លាក់ទៅ ក្នុងអបាយទាំងឡាយ ដូចដើមឈើត្រូវពួរជ្រែរួបរឹតឲ្យដួលចុះលើផែនដីដូច្នោះ, ទើបឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាសដូចជាចោរ អ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាសដូច្នោះឯង ។

ក្នុងវេលាចប់ធម៌ទេសនា ជនជាច្រើន សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

( រឿងព្រះទេវទត្ត ចប់ )

****************

# ៧ រឿងការខ្វល់ខ្វាយដើម្បីនឹងបំបែកសង្ឃ

## សេចក្ដីខាងដើម

ព្រះសាស្ដា ស្ដេចនៅវេឡុវ័ន ទ្រង់ប្រារព្ធការខ្វល់ខ្វាយដើម្បីនឹងបំបែកសង្ឃ ត្រាស់ព្រះធម្មទេសនានេះថា “**សុករានិ**” ជាដើម ។

## ព្រះទេវទត្តព្យាយាមបំបែកសង្ឃ

សេចក្ដីពិស្ដារថា ថ្ងៃមួយ ព្រះទេវទត្តខ្វល់ខ្វាយដើម្បីនឹងបំបែកសង្ឃ ឃើញព្រះអានន្ទត្ថេរកំពុងត្រាច់បិណ្ឌបាត ក៏ប្រាប់បំណងរបស់ខ្លួន ។ ព្រះថេរៈស្ដាប់ដំណឹងនោះហើយ ទៅកាន់សំណាក់របស់ព្រះសាស្ដា បានទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គ វេលាព្រឹកខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រត្រង់វេឡុវ័ននេះហើយ ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត, បពិត្រព្រះអង្គ ទេវទត្តបានឃើញខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយ ចូលទៅរកខ្ញុំព្រះអង្គបានពោលពាក្យនេះថា អាវុសោ អានន្ទ ចាប់ផ្ដើមអំពីថ្ងៃនេះខ្ញុំនឹងធ្វើឧបោសថ និងសង្ឃកម្មបែកអំពីព្រះមានព្រះភាគ និង

កិច្ចសង្ឃ, បពិត្រព្រះមានព្រះភាគ ថ្ងៃនេះ ទេវទត្តនឹងបំបែកសង្ឃ គឺនឹងធ្វើឧបោសថ និងសង្ឃកម្ម ។

## សេចក្ដីល្អមនុស្សល្អធ្វើងាយ

កាលព្រះអានន្ទក្រាបទូលដូច្នោះហើយ ព្រះសាស្ដាទ្រង់បន្លឺព្រះឧទានថា ៖

សេចក្ដីល្អ មនុស្សល្អធ្វើងាយ, សេចក្ដីល្អ មនុស្សអាក្រក់ធ្វើលំបាក, សេចក្ដីអាក្រក់ មនុស្សអាក្រក់ធ្វើងាយ, សេចក្ដីអាក្រក់ អរិយបុគ្គលធ្វើបានដោយកម្រ

ហើយត្រាស់ថា ម្នាលអានន្ទ ឈ្មោះថា កម្មដែលមិនជាប្រ-យោជន៍ដល់ខ្លួន ធ្វើបានងាយ, កម្មដែលជាប្រយោជន៍ដល់ខ្លួនធ្វើបានដោយលំបាកពន់ពេក ហើយត្រាស់ព្រះគាថានេះថា ៖

**៧ សុករានិ អសាធូនិ អត្តនោ អហិតានិ ច**
**យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។**

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណា ជាប្រយោជន៍ផង ល្អផង កម្មនុ៎ះឯងដែលជនពាលធ្វើបានដោយលំបាក ។

# អធិប្បាយគាថា

ព្រះគាថានោះមានសេចក្ដីថា ៖

កម្មទាំងឡាយណា មិនល្អ គឺមានទោស ទាំងជាផ្លូវអបាយ ឈ្មោះថា មិនជាប្រយោជន៍ដល់ខ្លួន ព្រោះធ្វើនោះឯង កម្មទាំងនោះធ្វើងាយ ។ ចំណែកកម្មណា ឈ្មោះថា ជាប្រយោជន៍ដល់ខ្លួន ព្រោះធ្វើ ឈ្មោះថា ល្អ ដោយអត្ថថា គ្មានទោស គឺជាផ្លូវសុគតិ ទាំងជាផ្លូវព្រះនិព្វាន, កម្មនោះធ្វើសែនលំបាក ដូចបង្វែរទឹកស្ទឹងគង្គាដែលហូរទៅទិសឯកើត ធ្វើឲ្យងាកមុខត្រឡប់ដូច្នោះ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន សំរេចលោកុត្តរផលមានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

( រឿងការខ្វល់ខ្វាយដើម្បីទីងបំបែកសង្ឃ ចប់ )

*****************************

# ៨ រឿងព្រះកាលត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះ-កាលត្ថេរ បានត្រាស់ព្រះធម្មទេសនានេះថា **“យោ សាសនំ”** ជាដើម ។

## ព្រះថេរៈមិនឲ្យឧបដ្ឋាយិកាទៅស្ដាប់ធម៌

ដូចបានឮមក ស្ដ្រីម្នាក់ក្នុងក្រុងសាវត្ថី តាំងនៅក្នុងទីនៃមាតា ទំនុកបំរុងព្រះថេរៈអង្គនោះ ។ ពួកមនុស្សក្នុងផ្ទះនៃអ្នកស្និទ្ធស្នាលរបស់ស្ដ្រីនោះ ស្ដាប់ធម៌ក្នុងសំណាក់ព្រះសាស្ដាហើយ ត្រឡប់មកផ្ទះហើយសរសើរថា ឱ ! ឈ្មោះថាព្រះពុទ្ធទាំងឡាយអស្ចារ្យហ្ន៎, ឱ ! ព្រះធម្មទេសនាក៏ពីរោះ ។ ស្ដ្រីនោះ ស្ដាប់ពាក្យរបស់ជនទាំងនោះហើយ ក៏ប្រាប់ដល់ព្រះកាលៈថា លោកម្ចាស់ ខ្ញុំចង់ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាខ្លះ ។ លោកហាមនាងថា កុំទៅទីនោះឡើយ ។ ស្ដ្រីនោះ ក្នុងថ្ងៃព្រឹកឡើង ក៏សូមទៀត សូម្បីត្រូវកាលៈនោះហាមដល់ទៅ ៣ ដង ក៏នៅតែចង់ស្ដាប់ធម៌នោះទៀត ។ មានពាក្យ

សួរជ្រែកចូលមកថា ចុះហេតុអ្វី បានជាលោកហាមនាង ? ឆ្លើយថា បានឮថា លោក មានគំនិតឃើញដូច្នេះថា បើឧបាសិកានេះ បានស្តាប់ធម៌ក្នុងសំណាក់ព្រះសាស្តាហើយ នឹងបែកចាកយើង ហេតុនោះ បានជាលោកហាមឃាត់នាង ។

ថ្ងៃមួយ ស្ត្រីនោះបរិភោគអាហារស្រេច សមាទានឧបោសថហើយ ផ្តាំបុត្រីទុកថា កូន ចូរអង្គាសលោកម្ចាស់ ឲ្យល្អ ហើយបានទៅវិហារអំពីព្រលឹម ។ ចំណែកបុត្រីរបស់នាង ក៏អង្គាសព្រះកាលៈដោយយកចិត្តទុកដាក់ ពេលលោកមកដល់នាងសួរថា មហាឧបាសិកាទៅណា ? ( នាង ) ប្រាប់ថា ទៅវិហារស្តាប់ធម៌ ។ លោកបានស្តាប់ដំណឹងនោះហើយ ក្តៅធ្លួល ព្រោះការក្អក់ចិត្តតាំងឡើងក្នុងផ្ទៃ ក៏នឹកថា ឥឡូវនេះ ឧបាសិកានោះបែកចាកអញហើយ ទៅយ៉ាងប្រញាប់ ឃើញស្ត្រីនោះស្តាប់ធម៌ក្នុងសំណាក់ព្រះសាស្តា ក៏ទូលព្រះសាស្តាថា ព្រះអង្គ ស្ត្រីនេះជាមនុស្សល្ងង់ មិនចូលចិត្តធម្មកថាដ៏ល្អិត, កុំត្រាស់ធម្មកថាដ៏ល្អិត ដែលប្រដាប់ដោយសភាវធម៌មានខន្ធជាដើមឡើយ ត្រាស់ត្រឹមតែទានកថា ឬសីលកថាដល់នាងក៏ល្មម ។

## សក្ការៈរមែងសំលាប់មនុស្សអាក្រក់

ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យរបស់លោកហើយ ត្រាស់ថា អ្នកជាមនុស្សឆោត អាស្រ័យទិដ្ឋិដ៏អាក្រក់ ហាមឃាត់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, អ្នកឯងព្យាយាមដើម្បីសំលាប់ខ្លួន ហើយត្រាស់ព្រះគាថានេះថា ៖

**៨ យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ**
**បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ**
**ផលានិ កណ្ដកស្សេវ អត្តឃញ្ញាយ ផល្លតិ ។**

បុគ្គលណា អប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនា របស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់ របស់បុគ្គលនោះ រមែងចេញផល ដើម្បីសំលាប់ខ្លួន ដូចផ្លែឬស្សីដូច្នោះ ។

## អធិប្បាយគាថា

ព្រះគាថានោះ មានសេចក្តីថា ៖

បុគ្គលណា ឆោត អាស្រ័យទិដ្ឋិដ៏អាក្រក់ ហាមប្រាមពួកជនដែលកំពុងពោលថា នឹងស្តាប់ធម៌ក្តី ថានឹងថ្វាយទានក្តី

ព្រោះ ខ្លាចអំពីការសូន្យសក្ការៈរបស់ខ្លួន ឈ្មោះថា ជំទាស់ពាក្យប្រៀនប្រដៅរបស់ព្រះអរិយបុគ្គល ដែលជាព្រះអរហន្ត ប្រព្រឹត្តទៅដោយធម៌ គឺព្រះពុទ្ធជាម្ចាស់, ការជំទាស់និងទិដ្ឋិ ដ៏លាមកនោះ របស់បុគ្គលនោះ រមែងដូចជាផ្លែរបស់ឈើមានបន្លា ពោលគឺដើមឫស្សី, ហេតុនោះ ដើមឫស្សី កាលផ្លែ រមែងផ្លែដើម្បីសំលាប់ខ្លួនប៉ុណ្ណោះ, យ៉ាងណា សូម្បីបុគ្គលនោះ ក៏រមែងកើតមកដើម្បីសំលាប់ខ្លួន គឺថា កើតមកដើម្បីបំផ្លាញខ្លួនឯងដូច្នោះ ។ សមពិត សូម្បីគាថាប្រពន្ធនេះ ព្រះមានព្រះភាគក៏បានត្រាស់ទុកថា ៖

ផ្លែចេក តែងសំលាប់ដើមចេកចោល ផ្លែឫស្សី
តែងសំលាប់ដើមឫស្សីចោលផ្លែបបុសតែងសំលាប់
ដើមបបុសចោល កូនក្នុងគភ៌តែងសំលាប់មេសេះ
អស្សតរ ចោលយ៉ាងណា, សក្ការៈក៏រមែងសំលាប់
បុរសអាក្រក់ ដូច្នោះ ។

ក្នុងវេលាចប់ទេសនា ឧបាសិកាតាំងនៅក្នុងសោតាបត្តិផល ទេសនាបានមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយដូច្នោះឯង ។

( រឿងកាលគ្គេរ ចប់ )

******************

## ៩ រឿងឧបាសកឈ្មោះចុល្លកាល

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបាសឈ្មោះចុល្លកាល ត្រាស់ព្រះធម្មទេសនានេះថា “**អត្តនាវ កតំ បាបំ**” ជាដើម ។

### ចុល្លកាលត្រូវចោទថាជាចោរ

ដូចបានឮមក ថ្ងៃមួយ ពួកចោរជីកឧម្មង្គ ត្រូវពួកម្ចាស់ទ្រព្យដេញតាមក៏ទំលាក់បង្វេចទ្រព្យទុកខាងមុខឧបាសកដែលស្តាប់ធម្មកថាក្នុងវិហារមួយរាត្រី ហើយដើរចេញមកពីវិហារអំពីព្រលឹមមកកាន់ក្រុងសាវត្ថី ក៏លួចរត់គេចចេញទៅ ដោយន័យដែលពោលហើយ ក្នុងរឿងមហាកាលនោះឯង ។ ពួកមនុស្សឃើញគាត់ហើយនិយាយថា មនុស្សនេះធ្វើចោរកម្ម

ពេលរាត្រីហើយ មកធ្វើដូចជាស្តាប់ធម៌, អ្នកទាំងឡាយ ចូរជួយចាប់វាទុក ហើយក៏វាយឧបាសកនោះ ។

## ចុល្លកាលអត់ស្លាប់ព្រោះនាងកុម្ភទាសីជួយ

ពួកនាងកុម្ភទាសី ដើរទៅកំពង់ទឹក ប្រទះហេតុនោះ ក៏ពោលថា នាយ លោកទាំងឡាយចូរចៀសចេញទៅ, អ្នកនេះមិនបានធ្វើកម្មបែបនេះទេ ហើយឲ្យមនុស្សទាំងនោះលែងគាត់មកវិញ ។ ឧបាសកទៅកាន់វិហារ ប្រាប់ដល់ភិក្ខុទាំងឡាយថា លោកម្ចាស់ ខ្ញុំព្រះករុណា ត្រូវមនុស្សទាំងឡាយឲ្យវិនាសហើយ, ខ្ញុំករុណាបានជីវិត ព្រោះអាស្រ័យពួកនាងកុម្ភទាសី ។ ភិក្ខុទាំងឡាយ ក៏ក្រាបទូលរឿងនោះដល់ព្រះតថាគត ។

## សៅហ្មងឬមិនសៅហ្មងព្រោះខ្លួនឯង

ព្រះសាស្តា ទ្រង់សណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លកាលឧបាសក បានជីវិត ព្រោះអាស្រ័យពួកនាងកុម្ភទាសី និងការដែលខ្លួនមិនមែនអ្នកធ្វើ, ព្រោះថា ធម្មតាសត្វទាំងនេះ ធ្វើបាបកម្មដោយខ្លួនឯងហើយ រមែងសៅហ្មងដោយខ្លួនឯង ក្នុងអបាយ មាននរកជាដើម, ចំណែកសត្វទាំងឡាយ ធ្វើកុសលហើយ ទៅកាន់សុគតិ

និងនិព្វាន ឈ្មោះថា បរិសុទ្ធបានដោយខ្លួនឯង ហើយត្រាស់ព្រះគាថានេះថា ៖

៩ អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធពុំបានទេ ។

## អធិប្បាយគាថា

ព្រះគាថានោះ មានសេចក្តីថា ៖

អកុសលកម្ម ជាកម្មដែលអ្នកណាធ្វើហើយ ដោយខ្លួនឯង, អ្នកនោះកាលសោយទុក្ខក្នុងអបាយ ៤ ឈ្មោះថា សៅហ្មងដោយខ្លួនឯង, ចំណែកបាបដែលអ្នកណាមិនបានធ្វើដោយខ្លួនឯង, អ្នកនោះកាលទៅកាន់សុគតិ និងនិព្វាន ឈ្មោះថា រមែងបរិសុទ្ធដោយខ្លួនឯង, សេចក្តីបរិសុទ្ធ ពោលគឺកុសលកម្ម និងសេចក្តីមិនបរិសុទ្ធ ពោលគឺអកុសលកម្ម ជារបស់

ចំពោះខ្លួន គឺរមែងឲ្យផលចំពោះខ្លួន របស់សត្វអ្នកធ្វើទាំង-ឡាយ ។ បុគ្គលដទៃ ធ្វើបុគ្គលដទៃឲ្យបរិសុទ្ធមិនបាន គឺឲ្យហ្មត់ហ្មង់មិនបានឡើយ ឲ្យសៅហ្មងមិនបានឡើយ ។

ក្នុងវេលាចប់ទេសនា ចុល្លកាលតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម្មទេសនា បានមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នា ដូច្នេះឯង ។ល។

( រឿងឧបាសកឈ្មោះចុល្លកាល ចប់ )

********************

## ១០ រឿងព្រះអត្តទត្ថត្ថេរ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះ-អត្តទត្ថត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា "**អត្តទត្ថំ បរត្ថេន**" ជាដើម ។

### ព្រះថេរៈព្យាយាមបំពេញប្រយោជន៍

ដូចបានឮមក កាលព្រះសាស្ដាត្រាស់ក្នុងកាលជិតនឹងបរិនិព្វានថា "ម្នាលភិក្ខុទាំងឡាយ អំណឹះ ៤ ខែទៀតអំពីថ្ងៃនេះ តថាគតនឹងបរិនិព្វាន" ភិក្ខុប្រមាណ ៧០០ រូប ដែលនៅជាបុថុជ្ជនកើតសេចក្ដីសង្វេគ មិនលះសំណាក់ព្រះសាស្ដាឡើយ ត្រាច់ប្រឹក្សាគ្នាថា អ្នកមានអាយុ ពួកយើងនឹងធ្វើដូចម្ដេចហ្ន៎ ។

ចំណែកព្រះអត្តទត្ថត្ថេរគិតថា ឮថា ព្រះសាស្ដានឹងបរិ-និព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត, ក៏ខ្លួនយើងនៅជាអ្នកមានរាគៈ, កាលព្រះសាស្ដានៅទ្រង់ព្រះជន្មនៅនេះឯង យើងនឹងព្យាយាមដើម្បីព្រះអរហត្ត ។ ព្រះថេរៈនោះ ទើបមិនបាន

ទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អ្នកមានអាយុ ហេតុអ្វី ទើបលោកមិនមកសំណាក់របស់ពួកខ្ញុំ, លោកមិនប្រឹក្សាអ្វីៗ ? ហើយក៏នាំទៅកាន់សំណាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុរូបនេះធ្វើយ៉ាងនេះ ។

ព្រះអត្តទត្ថត្ថេរនោះ សូម្បីព្រះសាស្តាត្រាស់ថា ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ឮថាព្រះអង្គនឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែទៀត, ខ្ញុំព្រះអង្គព្យាយាមដើម្បីសំរេចព្រះអរហត្ត ក្នុងកាលព្រះអង្គនៅទ្រង់ព្រះជន្មនៅនេះឯង ។

## អ្នកបដិបត្តិធម៌ឈ្មោះថាបូជាព្រះសាស្តា

ព្រះសាស្តាប្រទានសាធុការដល់ព្រះថេរៈនោះហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកណាស្រឡាញ់តថាគត, អ្នកនោះគួរដូចជាអត្តទត្ថ ព្រោះថា ជនទាំងឡាយបូជាដោយវត្ថុទាំងឡាយផ្សេងៗ មានគ្រឿងក្រអូបជាដើម មិនឈ្មោះថាបូជាតថាគតឡើយ, តែអ្នកបូជាដោយការបដិបត្តិធម៌ដ៏សមគួរដល់

ធម៌ ទើបឈ្មោះថាបូជាតថាគត, ព្រោះដូច្នោះ សូម្បីភិក្ខុរូបដទៃ ក៏គប្បីដូចជាអត្តទត្ថ ហើយត្រាស់ព្រះគាថានេះថា ៖

១០ អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។

បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ( នោះ ) ។

## អធិប្បាយគាថា

គាថានោះមានសេចក្តីថា ៖

បុគ្គលជាគ្រហស្ថ មិនគប្បីធ្វើប្រយោជន៍របស់ខ្លួន សូម្បីមួយកាកណិកឲ្យវិនាស ព្រោះតែប្រយោជន៍ របស់អ្នកដទៃ សូម្បី ១០០០ ក៏ដោយ ។ ព្រោះថា ប្រយោជន៍របស់ខ្លួននៃបុគ្គលនោះឯង សូម្បីត្រឹមមួយកាកណិក ក៏នៅជារបស់គួរទំពាស៊ី ឬ បរិភោគឲ្យសំរេចបាន, ប្រយោជន៍របស់អ្នកដទៃឲ្យសំរេចមិនបាន ។ ចំណែកពីរបាទព្រះគាថានេះ ព្រះមានព្រះភាគមិនត្រាស់យ៉ាងនោះ ត្រាស់ដោយលំនាំនៃកម្មដ្ឋាន

ប៉ុណ្ណោះ ។ ព្រោះដូច្នោះ ភិក្ខុតាំងចិត្តថា យើងនឹងមិនញ៉ាំង ប្រយោជន៍របស់ខ្លួនឲ្យវិនាស ដូច្នេះហើយ ក៏មិនគប្បីញ៉ាំង កិច្ចមានការជួសជុល ព្រះចេតិយជាដើម ដែលកើតឡើងដល់ សង្ឃ ឬវត្ត មានឧបជ្ឈាយវត្តជាដើមឲ្យវិនាស, ព្រោះថា ភិក្ខុ បំពេញអភិសមាចារិកវត្តឲ្យបរិបូណ៌ រមែងធ្វើឲ្យជាក់ច្បាស់ នូវផលទាំងឡាយ មានអរិយផលជាដើម ។ ព្រោះដូច្នោះ ការបំពេញវត្តឲ្យបរិបូណ៌នេះឯង ទើបឈ្មោះថា ជាប្រយោជន៍ របស់ខ្លួនពិត ។

ម្យ៉ាងទៀត ភិក្ខុណា មានវិបស្សនាប្រារព្ធយ៉ាងខ្លាំងក្លា ហើយ ប្រាថ្នាការចាក់ធ្លុះថា យើងនឹងចាក់ធ្លុះក្នុងថ្ងៃនេះៗ ឯង ដូច្នេះហើយ ប្រព្រឹត្តព្យាយាម, ភិក្ខុនោះ សូម្បីញ៉ាំងវត្ត មាន ឧបជ្ឈាយវត្តជាដើមឲ្យវិនាសហើយ ក៏គប្បីធ្វើកិច្ចរបស់ខ្លួនឲ្យ បាន ។ ក៏ភិក្ខុដឹងច្បាស់ប្រយោជន៍របស់ខ្លួនបែបនោះ គឺកំណត់ បានថា នេះជាប្រយោជន៍របស់ខ្លួន គប្បីជាអ្នកខ្វល់ខ្វាយប្រកប ក្នុងប្រយោជន៍របស់ខ្លួននោះ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈនោះ បានតាំងនៅក្នុងអរហត្តផល ។ ទេសនាបានជាប្រយោជន៍ ដល់ភិក្ខុអ្នកប្រជុំគ្នាទាំងឡាយ ដូច្នេះឯង ៕

រឿងព្រះអត្តទត្ថត្ថេរ ចប់

អត្តវគ្គវណ្ណនា ចប់

វគ្គទី ១២ ចប់

********